ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Note Case of Thai

Lao

30 year

(applied law

**តុលាការកំពូល**

**សាលដីកា**

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

**សភាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ ២៩

ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១

**សាលដីកា**

លេខ ២៧ IV

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.លោកជំទាវ [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រម

៤.ឯកឧត្តម [redacted] ចៅក្រម

៥.លោកជំទាវ [redacted] ចៅក្រម

**ចៅក្រមរបាយការណ៍**

លោកជំទាវ [redacted]

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted]

* ...why ..Thai .30 years

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្ដឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] DONG ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០០៣/០០១ "ក្រ.I.ព្រ.ទ" ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ព្រះសីហនុដែលមាន៖

**អ្នកប្ដឹងសាទុក្ខ ៖** ជនជាប់ចោទឈ្មោះ [redacted] DONG ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិចិន មុខរបរជាងសំណង់ មានទីកន្លែងកំណើតនៅប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅសង្កាត់លេ[redacted]ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted] មានកូនចំនួន ០៤នាក់ ជាទីតិជន ទោសពីមុនគ្មាន។



Scanned with CamScanner

មេធាវីការពារសិទ្ធិលោក [redacted] ម៉ូរ៉ា

**បុគ្គលដែលជាប់ពាក់ព័ន្ធ៖**

១.ជនជាប់ចោទឈ្មោះ [redacted] GUO ភេទប្រុស កើតឆ្នាំ១៩៧៧ ជនជាតិចិន មុខរបរជាងសំណង់ មានទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួននៅសង្កាត់ [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] -ម- ម្ដាយឈ្មោះ [redacted] -ម- ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់។ ជាទីតិជន។ ទោសពីមុនគ្មាន។

២.ជនជាប់ចោទឈ្មោះ [redacted] XINHAI ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិចិន មុខរបរមិនពិតប្រាកដ មានទីកន្លែងកំ[redacted] ប្រទេសចិន មានទីលំនៅ [redacted] ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាន់លិខិតឆ្លងដែនលេខ EC9816583 ។

**ជាប់ចោទពីបទ** ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុម ៤ ភូមិ ៣ សង្កាត់លេខ ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ជនជាប់ចោទឈ្មោះ [redacted] HAO ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិចិន មុខរបរចូលហ៊ុនបើកផ្សារ និងផ្ទះសំណាក់ មានទីកន្លែងកំណើតនៅ ខេត្តហ្វូជៀង ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅ[redacted] ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] -ម- ម្ដាយឈ្មោះ [redacted] -ម- ប្រពន្ធឈ្មោះ[redacted] មានកូនចំនួន ០១នាក់ ជាទីតិជន។ ទោសពីមុនគ្មាន។

៤.ជនជាប់ចោទឈ្មោះ[redacted] PI ភេទស្រី កើតឆ្នាំ១៩៨០ ជនជាតិចិន មុខរបរអ្នកគួបជេរជី និងផ្ទះ មានទីកន្លែងកំណើតនៅខេត្តគ័ងទង់ ប្រទេសចិន មានទីលំនៅមុនពេលឃាត់ខ្លួននៅជិតផ្សារលើ [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] -ម- ម្ដាយឈ្មោះ [redacted] -ម- មេម៉ាយ មានកូនចំនួន ០២ នាក់ ជាទីតិជន។ ទោសពីមុនគ្មាន។

**ជាប់ចោទពីបទសមគំនិតក្នុងអំពើជួញដូរនិងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្រុម ៤ ភូមិ ៣ សង្កាត់លេខ ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ១៥ នាទី ស្ថិតនៅចំណុចផ្ទះសំណាក់ព្រីនសេស ក្នុងក្រុមទី ៤ ភូមិ ៣ សង្កាត់លេខ ២ ក្រុងព្រះសីហនុ មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន,រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងសមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនមួយកើតឡើង ដែលផ្ដើមចេញពីករណីអគ្គិភ័យនៅចំណុចខាងលើនៅពេលសមត្ថកិច្ចចូលទៅពន្លត់ និងត្រួតពិនិត្យតាមបន្ទប់នីមួយៗដែលបានរងការខូចខាតដោយអគ្គិភ័យ ឃើញថា បន្ទប់លេខ C៣៦ មានសំណាកសង្ស័យចំនួន ០២ដុំ រួមមាន ថ្នាំគ្រាប់ WY ចំនួន ៥០ ដុំ មានចំនួន ៣០០,០០០ គ្រាប់ ទម្ងន់ ២៧,៥៤៣ ក្រាម និងម្សៅក្រាមពណ៌សថ្លាជាសារធាតុញៀនប្រភេទកេតាមីនមួយកញ្ចប់ធំចំនួន ១,០៤៧,៣៦ ក្រាម (ថ្លឹងទាំងសំបក) ហើយសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យពីរនាក់ទៀតឈ្មោះ[redacted] HAO ភេទប្រុស ជនជាតិចិន និងឈ្មោះ [redacted] PI ភេទស្រី ជនជាតិចិន ដោយពួកគេបានសារភាពថាម្ចាស់ បន្ទប់លេខ C៣៦ មានឈ្មោះ [redacted] XINHAI ភេទប្រុស ជនជាតិចិន។ ក្រោយមកនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ កម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតស្រាលបានបង្ក្រាប និងឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់។ មានឈ្មោះ [redacted] DONG ភេទប្រុស ជនជាតិចិន និងឈ្មោះ [redacted] GUO ភេទប្រុស ជនជាតិចិន ពាក់ព័ន្ធនឹងករណីប្រើប្រាស់អាវុធខុសច្បាប់ដោយឡែកឆែករកឃើញគ្រឿងញៀនម្សៅក្រាមសថ្លាចំនួន ០១ កញ្ចប់ធំ និងថ្នាំគ្រាប់ WY ចំនួន ០៦កញ្ចប់ នៅក្នុងកាបូបស្ពាយចំហៀងរបស់ឈ្មោះ[redacted] DONG ដោយពួកគេបានបញ្ជាក់ថា គ្រឿងញៀនដែលសមត្ថកិច្ចដកហូតបាននោះគឺជារបស់ឈ្មោះ [redacted] XINHAI ភេទប្រុស ជនជាតិចិន ដែលជាម្ចាស់បន្ទប់លេខ C៣៦ ដែលត្រូវភ្លើងនេះនោះ ហើយចំណុចនេះនាំឱ្យសមត្ថកិច្ចជំនាញសន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted] XINHAI ភេទប្រុស ជនជាតិចិន, ឈ្មោះ[redacted] DONG ភេទប្រុស ជនជាតិចិន និងឈ្មោះ [redacted] DUO ភេទប្រុស ជនជាតិចិន គឺជាបក្ខពួកតែមួយ។

**-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨៦៥/៥៨ (ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖**

១-ឲ្យឈ្មោះដូចខាងក្រោម ៖

ក.ឈ្មោះ[redacted] [redacted] PI ភេទស្រី កើតឆ្នាំ១៩៨០ ជនជាតិចិន (មានសាវតារជាតិខាងលើ) រួចខ្លួនពីបទចោទ ពីបទសមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ[redacted]លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ



Scanned with CamScanner

ខ.ឈ្មោះ [redacted]GUO ភេទប្រុស កើតឆ្នាំ១៩៧៧ ជនជាតិចិន (មានសាវតារជាតិខាងលើ) រួចខ្លួនពីបទចោទពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ[redacted]ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសជនជាប់ចោទ

ក.ឈ្មោះ [redacted] HAO ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិចិន (មានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ ៦០.០០០.០០០ (ហុកសិបលាន) រៀល ពីបទ បទសមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុម៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

ខ.ឈ្មោះ [redacted] DONG ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិចិន (មានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ ៦០.០០០០០០ (ហុកសិបលាន) រៀល

គ.ឈ្មោះ [redacted]XINHAI ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិចិន (មានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ មួយជីវិត និងពិន័យជាប្រាក់ ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុមទី៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.វត្ថុចាប់យកមាន ៖

ក.គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះ មេតំហ្វេតាមីន (ហៅត្រាយ៉ាបា ឬថ្នាំឆ្កួត) ចំនួនទម្ងន់ ២៧.៥៤៣ g × ១៣,៥១ / ១០០ ដែលមានបរិមាណភាពសុទ្ធស្មើនិង ៣,៧២១.០៥៩៣ ក្រាម

ខ .គ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ កេតាមីន ចំនួន ទម្ងន់ ១០៤៧,៣៦g×៤៧.៥៣ / ១០០ ដែលមានបរិមាណភាពសុទ្ធស្មើនិង ៤៩៧,៨១០២០៨ ក្រាម

គ.ទូរស័ព្ទ០២ គ្រឿង ម៉ាក IPHONE ពណ៌មាស និងម៉ាក HUAWEI ពណ៌បៃតងត្រូវរឹបអូស តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១០៧/១៩ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុលើឈ្មោះ [redacted] XINHAI ត្រូវអស់អានុភាពអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។

៥-បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន ឈ្មោះ [redacted] XINHAI ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិចិន មកអនុវត្តទោសនៅពន្ធនាគារខេត្តព្រះសីហនុ តាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] HAO, ឈ្មោះ [redacted] PI, ឈ្មោះ [redacted] GUO និងឈ្មោះ [redacted] DONG កំបាំងមុខឈ្មោះ [redacted] XINHAI និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១២៦ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] HAO ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៦៥/៩៨ (ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៣៩ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] DONG ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៦៥/៩៨(ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ០០៣/០០១ "ក្រ.I.ព្រ.ឧ" ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] HAO ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ និងពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] DONG ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៦៥/៩៨ (ឃ) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល លើកលែងតែចំណុចទី២ (២.ក) ត្រូវបានកែប្រែ និងសម្រេចជាថ្មីដូចខាងក្រោម៖

-ឱ្យឈ្មោះ [redacted] HAO រួចខ្លួនពីបទចោទពីបទ សមគំនិតក្នុងអំពើជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុមទី៤ ភូមិ៣ សង្កាត់លេខ២



Scanned with CamScanner

ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

សាលដីកានេះបើកសវនាការជាសាធារណៈ នៅថ្ងៃព្រហស្បតិ៍ ៣រោច ខែមិគសិរ ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] HAO និងឈ្មោះ [redacted] DONG។

ទុកសិទ្ធិប្តឹងសាទុកតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] DONG ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ០០៣/០០១-ក្រ.I.ព្រ.ទ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា សាលាដំបូង និងសាលាឧទ្ធរណ៍បានសម្រេចត្រឹមត្រូវតាមច្បាប់ហើយ។ ទោះបីជនជាប់ចោទបានឆ្លើយថា ខ្លួនមិនបានដឹងអ្វីទាំងអស់ក្នុងករណីគ្រឿងញៀននៅសណ្ឋាគារព្រើនសេស ប៉ុន្តែពុំមានកស្តុតាងដោះបន្ទុកឡើយ។ ផ្ទុយមកវិញនៅពេលសមត្ថកិច្ចបានឃាត់ខ្លួន និងបានដកហូតគ្រឿងញៀនជាក់ស្តែងពីឈ្មោះ [redacted] DONG នៅសណ្ឋាគារព្រើនសេស ជារបស់ឈ្មោះ [redacted] HAI គឺជាប្រភេទគ្រឿងញៀនដូចគ្នាបានន័យថា ជាបក្សពួកតែមួយជាមួយជនជាប់ចោទឈ្មោះ [redacted] DONG។ រាល់កស្តុតាងទាំងអស់បញ្ជាក់បានថា ជនជាប់ចោទពិតជាមានទំនាក់ទំនងគ្នាក្នុងការជួញដូរ និងរក្សាទុកគ្រឿងញៀនពិតប្រាកដ។ ដូច្នេះមានពិរុទ្ធភាពគ្រប់គ្រាន់ពីបទ ជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច ៖

១.ទទួលបណ្តឹងសាទុក្ខលេខ០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] DONG ទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងអង្គច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០០៣/០០១-ក្រ.I.ព្រ.ទ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ទុកជាបានការដដែល។



Scanned with CamScanner

-លោក [redacted] ប៉ូក មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] DONG បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនបានសារភាពនៅសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍ថា ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ មានអង្គហេតុពីរ ទី១ [redacted] HAI ត្រូវជាបងថ្លៃរបស់កូនក្ដីខ្លួនបានឈ្លោះគ្នាជាមួយ និងប្រពន្ធ ហើយពេលនោះមានការប្រតាយប្រតប់គ្នា ហើយជ្រុះកាបូប បន្ទាប់មកកូនក្ដីខ្លួនបានរើសកាបូបនោះ។ ទី២ មានការឆេះបន្ទប់ដែលឈ្មោះ [redacted] HAI ស្នាក់នៅ ហើយរកឃើញមានកាកសំណល់គ្រឿងញៀនដែលដូចគ្នានឹងគ្រឿងញៀនក្នុងកាបូបរបស់ [redacted] HAI ក៏មានការចោទប្រកាន់ទៅលើកូនក្ដីថា ជាបក្សពួកនឹងគ្នាតែម្ដង ពីព្រោះថា កូនក្ដីខ្លួន និងឈ្មោះ [redacted] HAI ជាបងប្អូននឹងគ្នា។ ជាតុផ្សំនៃបទល្មើសកូនក្ដីខ្លួនត្រូវបានចោទពីបទ រក្សាទុក និងជួញដូរគ្រឿងញៀន ប៉ុន្តែគ្មានឯកសារកស្តុតាងណាមួយបញ្ជាក់ថា កូនក្ដីខ្លួនជាអ្នកធ្វើនោះទេ។ ជាតុផ្សំនៃបទល្មើសវាពុំមានទេ ប៉ុន្តែបែរជារកឃើញថា មានបទល្មើសទៅវិញ, ជាសរុបមកខ្លួនយល់ថា មិនមានបទល្មើសគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើកូនក្ដីខ្លួនឡើយ។ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូល បង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ LANG XIAO DONG

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលជនជាប់ចោទឈ្មោះ [redacted] DONG មិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់តុលាការអង្គសេចក្ដី ដែលសម្រេចផ្ដន្ទាទោសខ្លួនពីបទ ជួញដូរ និងរក្សាទុកគ្រឿងញៀន ដោយអះអាងជាចម្បងថា ខ្លួនត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន ៥ឆ្នាំ ម្ដងរួចហើយ ដូចនេះ តាមមាត្រា ២២ នៃក្រមព្រហ្មទណ្ឌក្នុងសំណុំរឿងនេះ ខ្លួនមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទៀតទេ ខ្លួនសុំឱ្យក្រុមប្រឹក្សាឱ្យខ្លួនរួចពីបទចោទ ក្នុងករណីគ្រឿងញៀននៅសណ្ឋាគារព្រីនសេសនោះ តុលាការកំពូលពិនិត្យឃើញថា ៖

-អង្គហេតុនៅក្នុងសំណុំរឿងនេះគឺ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលត្រូវបានតុលាការថ្នាក់ក្រោម បង្កសំណុំរឿងថ្មីមួយទៀត ផ្សេងពីសំណុំរឿងក្នុងអង្គហេតុទី០២



Scanned with CamScanner

ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលជនជាប់ចោទបានអះអាងខាងលើ។ ដូច្នេះ តាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ តុលាការអាចធ្វើការចោទប្រកាន់ជាច់ពីគ្នាបាន។

-ការចោទប្រកាន់ និងជំនុំជម្រះក្នុងអង្គហេតុថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ត្រូវបានសាលាដំបូង ក៏ដូចជាសាលាឧទ្ធរណ៍ សម្រេចសេចក្តីដោយមានសំអាងហេតុត្រឹមត្រូវតាមច្បាប់ហើយ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ [redacted] DONG មិនមានមូលហេតុដូចដែលបានកំណត់ក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៤-យល់ឃើញថា សាលដីកាលេខ ០០៣/០០១ "ក្រ.l.ព្រ.ទ" ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០២០ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ត្រឹមត្រូវទើងគតិច្បាប់។

**ហេតុដូច្នេះ**
**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ ០៤ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ជនជាប់ចោទ [redacted] DONG ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០០៣/០០១"ក្រ.l.ព្រ.ទ" ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ព្រះសីហនុទាំងមូល។

សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២។

| | | |
|---|---|---|
| -លោកជំទាវ | [redacted] | ប្រធាន |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -ឯកឧត្តម | [redacted] | ចៅក្រម |
| -លោកជំទាវ | [redacted] | ចៅក្រម |
| -កញ្ញា | [redacted] | ក្រឡាបញ្ជី |

**បានឃើញ**

ថ្ងៃពុធ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner